# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ......៧៤០......អ.ន.ក

ថ្ងៃ.ច័ន្ទ.....៣កើត.....ខែ.ពិសាខ.ឆ្នាំ.កុរ.ឯកស័ក.....ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.....០៦.....ខែ.ឧសភា......ឆ្នាំ២០១៩...

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំត្រីមាសទី១ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ មានដូចខាងក្រោម៖

I. **លទ្ធផលបញ្ចប់ការងារដាំដុះដំណាំកសិកម្មរដូវប្រាំងឆ្នាំ២០១៨-២០១៩** (គិតត្រឹមថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៥៩៦.៤៨៣ ហ.ត ស្មើនឹង១៣៣,២៩% នៃផែនការចំនួន ៤៤៣.៧០០ហ.ត ច្រើនជាងឆ្នាំមុនចំនួន ៤៧.៧២៨ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៦៣២.៩៤៩ ហ.ត ច្រើនជាងឆ្នាំមុនចំនួន ៧១.៨៨១ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៦២៥.៩០៩ ហ.ត ស្មើនឹង៩៨,៨៨%
- ផ្ទៃដីសាបសរុប : ១៧២ ហ.ត តិចជាងឆ្នាំមុនចំនួន ៣០៤ ហ.ត
- ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩ : នៅក្នុងត្រីមាសទី១នេះ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដី ៥៩៣.៧៤៧ ហ.ត ស្មើនឹង ៩៩,៥៤% នៃផ្ទៃដីអនុវត្ត ដែលទទួលបានទិន្នផលមធ្យម ៤,៥១២ តោន/ហ.ត និងបរិមាណផលសរុប ២.៦៧៨.៨៤៣ តោន។







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវប្រាំងពីឆ្នាំ២០១៥-២០១៩ គិតត្រឹម ត្រីមាសទី១នៃឆ្នាំ*



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427